ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

១១១១១១

តុលាការកំពូល

---------

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១៣

ចុះថ្ងៃទី១៦ - ០២ - ១៩៩៩

សាលដីកា

លេខ : ៣៥

ចុះថ្ងៃទី២៧ - ១០ - ១៩៩៩

## តាងនាមប្រជារាស្ត្រខ្មែរ

## តុ លា កា រ កំ ពូ ល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ២៧ ខែ-តុលា ឆ្នាំ១៩៩៩ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | ឌិត | មុន្ទី - | ប្រធាន |
| ២- | លោក | ឈឹម | ស៊ីផល | ចៅក្រម |
| ៣- | លោក | សោម | សិរីវឌ្ឍ | ចៅក្រម |
| ៤- | លោក | ប្រាក់ | គឹមសាន | ចៅក្រមរេឡាយការណ៍ |
| ៥- | លោក | យស់ | សុខឿន | ចៅក្រម |
| | លោក | ប៉ុល | វណ្ណា | ក្រឡាបញ្ជី |
| | | តំណាងមហាអយ្យការ | | |
| | លោក | សាយ | សារី | ព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ៤០ ចុះថ្ងៃទី ១១ - ៥ - ៩៨ របស់លោកថ្នាំ ចន្ទតារា ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ២០០ ចុះថ្ងៃទី ១១ - ៥ - ៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ ១៣ ចុះថ្ងៃទី១៦ - ០២ - ៩៩ របស់តុលាការកំពូល ។

- ជនជាប់ចោទឈ្មោះ ហោ ស៊ីមឈាង " ចុងបណ្តឹងសាទុក្ខ " ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខ២៦១ ផ្លូវលេខ ៣១៦ សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

- ត្រូវចោទពីបទ : ក្លែងបន្លំលិខិតឯកជន និងប្រើប្រាស់ និង រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅភ្នំពេញ កាលពីខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ។ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥០ និង ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ មេធាវី លោក ទី ពៅ ។

- ដើមបណ្តឹងរដ្ឋប្បវេណី ក្រុមហ៊ុនភូទិនថលក្លឹប " ភ្នំពេញ " តំណាងដោយលោកថ្នាំ ចន្ទតារា ជំនួយការមេធាវីរាជរដ្ឋាភិបាលកម្ពុជា " ម្ចាស់បណ្តឹងសាទុក្ខ " ។

- តាមពាក្យបណ្តឹងចុះថ្ងៃទី១៥ - ៦ - ៩៨ របស់ឈ្មោះសេរ៉ូវ ជីអ៊ី ប្តឹងសុំចេញសេចក្តីសំរេចធ្វើការហាមឃាត់ ការលក់ឡាយឡុង ទីស្នាក់ការក្រុមហ៊ុន " ភ្នំពេញ ភូទិនថលក្លឹប " ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃទី ២៩ - ៦ - ៩៨ និង សុំផ្អាកការប្រគល់ប្រាក់ចំនួន បួនលានដុល្លារអាមេរិក ព្រមទាំងការប្រាក់ ២០ ម៉ឺនដុល្លារអាមេរិក ដោយហេតុថា សំណុំរឿងពីរមានបច្ច័យទំនាក់ទំនង ដូចជារឿង

ព្រហ្មទណ្ឌ មួយជារឿងរដ្ឋប្បវេណី ។ ដូច្នេះត្រូវរង់ចាំការសំរេចសេចក្ដីរឿងព្រហ្មទណ្ឌ ចូលជាស្ថាពរសិន ទើបអាចអនុវត្តសាលក្រមព្រមគ្នាតែម្ដង ។ ករណីនេះជារឿងព្រហ្មទណ្ឌផឹតរឿងរដ្ឋប្បវេណី ម្ខាងនេះទៀត លោក ទោ ស៊ីមលាង បានអះអាងថា លោក ឆ.ឃ ជីអន ជំពាក់ប្រាក់-៤លានដុល្លាអាមេរិក ហើយមកប្ដឹងទាមទារទ្រព្យសម្បត្តិស្របច្បាប់របស់ក្រុមហ៊ុន " ភ្នំពេញអូរិនថលក្លឹប " ទៅវិញ ប៉ុន្តែកិច្ចសន្យានេះត្រូវបាន ព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ និង បញ្ជូនអោយតុលាការ ធ្វើការស៊ើបអង្កេត ដើម្បីជំនុំជំរះទៅហើយ ។

- តាមពាក្យបណ្ដឹងរបស់លោក ច្បាល់ ចន្ទតារា ចុះថ្ងៃទី ០២ - ០២ - ៩៨ ប្ដឹងពីឈ្មោះ ឆ ឃ ជីអន និង ទោ ស៊ីមលាង ពីបទក្បត់សេចក្ដីទុកចិត្ត និង ក្លែងលិខិតឯកជន ដើម្បីយកទ្រព្យសម្បត្តិស្របច្បាប់ របស់ក្រុមហ៊ុនភ្នំពេញ អូរិនថលក្លឹប ចំនួន ០៤លានដុល្លាអាមេរិក ។

- បានឃើញ ដីកាសំរេចលេខ ២០៧០ត.ព្រ ចុះថ្ងៃទី ១៧ - ៦ - ៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារសេចក្ដីសំរេច ដូចតទៅ :

១ - ទទួលពាក្យបណ្ដឹងរបស់ឈ្មោះ ច្បាល់ ចន្ទតារា តំណាងអោយភាគីដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមហ៊ុន អូរិនថលក្លឹប ចុះថ្ងៃទី ១៥ - ៦ - ៩៨ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២ - ហាមឃាត់មិនអោយឈ្មោះ ទោ ស៊ីមលាង ទៅ កង លក់ដូរ - ផ្ទេរសិទ្ធិ ធ្វើអោយដល់អ្នកដទៃ នូវសណ្ឋាគារគ្រីនអូតែល ស្ថិតនៅមហាវិថីព្រះនរោត្តម សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ជាបណ្ដោះអាសន្ន ។

៣ - ឃាត់ប្រាក់ ចំនួនបួនលានដុល្លាអាមេរិក និង ប្រាក់ជម្ងឺចិត្ត ចំនួន ២សែនដុល្លាអាមេរិក ដែលក្រុមហ៊ុនអូរិនថលក្លឹបត្រូវសងទៅឈ្មោះ ទោ ស៊ីមលាង ទៅ កង ជាបណ្ដោះអាសន្ន ។

៤ - ឃាត់ការលក់ទ្រព្យខ្លួងអាគារ - ដី - ទីតាំងអូរិនថលក្លឹប ដែលមានទីតាំងលេខ ២១៧ - ២១៩ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និង ហាមឃាត់មិនអោយឈ្មោះ ទោ ស៊ីមលាង ទៅកង ធ្វើការផ្ទេរសិទ្ធិ - លក់ដូរ - ជួលបញ្ចាំ ធ្វើអំណោយទាន អ្នកដទៃ នូវអាគារ - ដី ទីតាំងអូរិនថលក្លឹប ទុកជាបណ្ដោះអាសន្ន ។

៥ - បើភាគីណាមិនសុខចិត្ត នឹងដីកាសំរេចនេះត្រូវប្ដឹងទៅសាលាឧទ្ធរណ៍ ក្នុងរវាង ១៥ថ្ងៃ គិតពីថ្ងៃ ដែលបានទទួលដំណឹងពីដីកានេះ ។

- បានឃើញ ដីកាលេខ ២០៧០ត.ព្រ ចុះថ្ងៃទី១៧ - ៦ - ៩៨ ត្រូវបានប្ដឹងទាស់ដោយលោក ច្បាល់ ចន្ទតារា ។

- បានឃើញ ដីកាសំរេចលេខ ២១៧០ត.ព្រ ចុះថ្ងៃទី ២៤ - ៦ - ៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារសេចក្ដីសំរេច ថា:

១ - ទទួលពាក្យបណ្ដឹងទាស់ទៅនឹងការរឹបអូសការលក់ទ្រព្យខ្លួង នូវ អាគារ - ដី - ទីតាំងអូរិនថលក្លឹបភ្នំពេញ ស្ថិតនៅដីឡូតិ៍លេខ ២១៧ - ២១៩ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន របស់ឈ្មោះ ច្បាល់ ចន្ទតារា តំណាងអោយឈ្មោះ សៀ ជីអ៊ី ប្រធានក្រុមហ៊ុន

អូរិនថលក្លឹប ចុះថ្ងៃទី ២៣-៦-៩៨ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បញ្ឈប់អ្នកអនុវត្តសាលក្រម មិនអោយធ្វើការលក់ឡាយឡុង នូវ អាគារ-ដី-ទីតាំងអូរិនថលក្លឹបភ្នំពេញ ដែលស្ថិតនៅដីឡូតិ៍ លេខ ២១៧-២១៩ ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ របស់ក្រុមហ៊ុនអូរិនថលក្លឹបភ្នំពេញ ជាបណ្តោះអាសន្ន តាមមាត្រា ៦៧-៦៨-៦៩ នៃច្បាប់ស្តីពីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី ។

ដីកាសំរេចនេះមានអានុភាពអនុវត្តភ្លាម ៗ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៥២"ក" ចុះថ្ងៃទី២៩-៦-៩៨ របស់ឈ្មោះ មុំ លុជ្យ មេធាវីរបស់ឈ្មោះ ហោ ស៊ីមឈាង ដែលមិនសុខចិត្តដី ដីកាសំរេចលេខ២០៧០ត.ព្រ ចុះថ្ងៃទី ១៧-៦-៩៨ និង លេខ ២១៥៩ ចុះថ្ងៃទី ២៥-៦-៩៨ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុច សេចក្តីសំរេច នៃដីកាសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា : សុំបដិសេធដីកាសំរេចរបស់តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ និង បង្វិលរឿងនេះទៅ តុលាការក្រុងភ្នំពេញវិញដើម្បីចាត់ការបន្ត ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ២០០ ចុះថ្ងៃទី ១១-៨-៩៨ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៩-៦-៩៨ របស់មេធាវី មុំ លុជ្យ ទុកជាត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់ ។

២- បដិសេធដីកាសំរេចលេខ ២០៧០ត.ព្រ ចុះថ្ងៃទី ១៧-៦-៩៨ និង លេខ-២១៥៩ត.ព្រ ចុះថ្ងៃទី ២៥-៦-៩៨ របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ចោលជាអសារបង់ ។

៣- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៤០ ចុះថ្ងៃទី ១១-៩-៩៨ របស់លោក ហ៊ាំ ចន្ទតារា ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ២០០ ចុះថ្ងៃទី ១១-៦-៩៨ របស់សាលាឧទ្ធរណ៍ លើសាលដីកាទាំងមូល ។

- បានឃើញ សារណា ចុះថ្ងៃទី ០៨-៤-៩៩ របស់លោក ហ៊ាំ ចន្ទតារា តំណាងអោយក្រុមហ៊ុនភ្នំពេញអូរិនថលក្លឹប ។

- បានឃើញ សារណាតប ចុះថ្ងៃទី ២១-៧-៩៩ របស់ លោក ទី ពៅ មេធាវីការពារអោយ លោក ហោ ស៊ីមឈាង ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលពេលសវនាការថា:

១- បណ្តឹងសាទុក្ខរបស់លោក ច្បាស់ ចន្ទតារា ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យ និង ពិចារណា ។

២- ទុកជាមោឃៈ សាលដីកាព្រហ្មទណ្ឌលេខ ២០០ ចុះថ្ងៃទី ១១-៩-៩៨ របស់សាលាឧទ្ធរណ៍ ។

- បានស្តាប់លោក ច្បាស់ ចន្ទតារា ដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការថា: ការចេញសាលដីកា របស់សាលាឧទ្ធរណ៍ធ្វើកបរបដិសេធនូវដីកាលេខ ២០៧០ ត.ព្រ ចុះថ្ងៃទី ១៧-៦-៩៨ និង ដីកាលេខ ២១៤៩ត.ព្រ ចុះថ្ងៃទី ២៤-៦-៩៨ របស់តុលាការក្រុងភ្នំពេញនោះ ធ្វើអោយប៉ះពាល់នូវទ្រព្យសម្បត្តិស្របច្បាប់របស់ក្រុមហ៊ុន ភ្នំពេញអូរិនថលក្លឹប យ៉ាងធ្ងន់ធ្ងរ ដែលរឿងក្តីព្រហ្មទណ្ឌនេះ តុលាការពុំទាន់ចាត់ការចប់សព្វគ្រប់ហើយមានហេតុ និង បច្ច័យពាន់ព័ន្ធ នឹងរឿងកិច្ចសន្យា នៃរឿងរដ្ឋប្បវេណីចាស់ ។

ខ្ញុំបាទក្នុងនាមតំណាងអោយក្រុមហ៊ុនភ្នំពេញអូរិនថលក្លឹប សូមសំណូមពរតុលាការកំពូលមេត្តាធ្វើការផ្តន្ទាទោសជនល្មើសអោយបានតឹងរឹងតាមច្បាប់និង សូមអោយតុលាការមេត្តាតំកល់ នូវ ដីកាលេខ ២០៧០ត.ព្រ ចុះថ្ងៃទី ១៧-៦-៩៨ និង ដីកាលេខ ២១៤៩ត.ព្រ ចុះថ្ងៃទី ២៤-៦-៩៨ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការទាំងមូល ដើម្បីធានានូវផលប្រយោជន៍ របស់យើងខ្ញុំ ។

- បានស្តាប់ សារណាតប របស់ជនជាប់ចោទឈ្មោះ ហោ ស៊ីមលាង ហៅ កង

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា : ពុំមានអ្វីបន្ថែមទៀតទេ រក្សាសេចក្តីសន្និដ្ឋានដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយ របស់ដើមបណ្តឹងរដ្ឋប្បវេណី សារណារបស់ជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤០ ចុះថ្ងៃទី ១៥-៩-៩៨ របស់លោកច្បាស់ ចន្ទតារា តំណាងអោយក្រុមហ៊ុនអូរិនថលក្លឹប ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ពិចារណាថាសាលដីការបស់តុលាការកំពូល ចូលជាស្ថាពរហើយនោះ គឺជាការភាន់ច្រឡំ ពីព្រោះថា សាលក្រមរដ្ឋប្បវេណីលេខ១០២ " ខ " ចុះថ្ងៃទី ១០-០១-៩៧ របស់តុលាការក្រុងភ្នំពេញដែលត្រូវបានសាលាឧទ្ធរណ៍សំរេចតម្កល់ទុកជាបានការ ទាំងមូល តាមអំណាចសាលដីការដ្ឋប្បវេណី លេខ ៥៩៥ ចុះថ្ងៃទី ០៧-១០-៩៧ ហើយដែលត្រូវបាន - តុលាការកំពូលសំរេចតម្កល់ ទុកជាបានការទាំងមូល តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ០៨ ចុះថ្ងៃទី

០៨-០១-៩៨ ដែលនោះ ជាសាលក្រមកំបាំងមុខ លោក ឆយ ជីអន ដែលទទួលមរណភាពមុនការ ប្រកាសសាលក្រមនេះទៅទៀត ដូច្នេះសាលដីការបស់តុលាការកំពូល ដែលចូលជាស្ថាពរហើយនោះ ចំពោះតែសេចក្តីសំរេចខ្លះប៉ុណ្ណោះ ប៉ុន្តែចំពោះសេចក្តីសំរេច ដែលទាក់ទិនដល់លោក ឆយ ជីអន ពុំទាន់ចូលជាស្ថាពរនៅឡើយ ហើយដែលពុំអាចយកទៅអនុវត្តបាននៅឡើយ ។

- យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាជូនមកតុលាការកំពូល និង បានទទួលដីកាកោះ ហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២០០ ចុះថ្ងៃទី ១១-៩-៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

១- ទទួលបណ្តឹងសាទុក្ខលេខ ៤០ ចុះថ្ងៃទី ១១-៩-៩៨ របស់ លោកប៉ាល់ ចន្ទតារា ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ២០០ ចុះថ្ងៃទី ១១-៩-៩៨ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ១៣ ចុះថ្ងៃទី ១៦-០២-៩៥ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ ។

៤- សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ២៧ ខែ តុលា- ឆ្នាំ ១៩៩៩ ។